PROMETRIC

# ការណែនាំប្រើប្រាស់

**កំណត់សំគាល់ពិសេស**

## តារាងមាតិកា

1. បទបញ្ញត្តិនៃការប្រឡង ..... 3
2. ការចុះឈ្មោះព័ត៌មានលម្អិតផ្ទាល់ខ្លួន ..... 5
3. ការប្រកាសលទ្ធផលប្រឡង ..... 6

# កំណត់សំគាល់ពិសេស

## 1. បទបញ្ញត្តិនៃការប្រឡង

<សិទ្ធិប្រឡង>

1. សិទ្ធិប្រឡង
ត្រូវមានអាយុ17ឆ្នាំពេញឡើងទៅគិតត្រឹមថ្ងៃប្រឡង(ចំពោះអ្នកមានសញ្ជាតិឥណ្ឌូនេស៊ីឬមីយ៉ាន់ម៉ាគឺអាយុ18ឆ្នាំពេញឡើងទៅ)។យ៉ាងណាមិញ ករណីប្រឡងនៅប្រទេសជប៉ុន គឺត្រូវតែជាអ្នកដែលមានសិទ្ធិប្រឡងដូចមានចែងក្នុង"គោលការណ៍ណែនាំអំពីការអនុវត្តការប្រឡងវាស់ស្ទង់សមត្ថភាពជំនាញកសិកម្ម"។

គោលការណ៍ណែនាំអំពីការអនុវត្តការប្រឡងវាស់ស្ទង់សមត្ថភាពជំនាញកសិកម្ម
<< https://www.nca.or.jp/upload/procedure_for_the_asat_km.pdf >>

2. បញ្ញត្តិអំពីការប្រឡងឡើងវិញ
អ្នកមិនអាចប្រឡងឡើងវិញបានទេរហូតទាល់តែកន្លងផុតទៅបាន45ថ្ងៃគិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃប្រឡង។

3. ប្រការត្រូវប្រុងប្រយ័ត្នដទៃទៀត
(1) ករណីប្រឡងនៅក្រៅប្រទេសជប៉ុន
នៅពេលអ្នកដែលគ្មានសញ្ជាតិរបស់ប្រទេសដែលអនុវត្តការប្រឡងបានដាក់ពាក្យប្រឡងនៅប្រទេសនោះ សភាកសិកម្មជាតិមិនធ្វើការធានាចំពោះការអាចប្រឡងបានឬអត់នោះទេ ព្រមទាំងមិនធានាថារបាយការណ៍ពិន្ទុក្នុងករណីប្រឡងជាប់គឺត្រូវបានទទួលស្គាល់ត្រឹមត្រូវជា"ឯកសារដាក់ពាក្យដែលពាក់ព័ន្ធការស្នើសុំទិដ្ឋាការទាក់ទងនឹងសមត្ថភាពជំនាញជាក់លាក់" ឬអត់នោះទេ។

(2) ករណីប្រឡងនៅក្នុងប្រទេសជប៉ុន
នៅពេលដែលអ្នកដែលគ្មានសញ្ជាតិរបស់ប្រទេសដែលបានចុះអនុស្សរណៈស្តីពីការសហប្រតិបត្តិការទ្វេភាគីពាក់ព័ន្ធនឹងសមត្ថភាពជំនាញជាក់លាក់ជាមួយប្រទេសជប៉ុន បានដាក់ពាក្យប្រឡង សភាកសិកម្មជាតិមិនធ្វើការធានាចំពោះការអាចប្រឡងបានឬអត់នោះទេ ព្រមទាំងមិនធានាថារបាយការណ៍ពិន្ទុក្នុងករណីប្រឡងជាប់គឺត្រូវបានទទួលស្គាល់ត្រឹមត្រូវជា"ឯកសារដាក់ពាក្យដែលពាក់ព័ន្ធការស្នើសុំទិដ្ឋាការទាក់ទងនឹងសមត្ថភាពជំនាញជាក់លាក់" ឬអត់នោះទេ។

<ការសាកសួរដែលពាក់ព័ន្ធនឹងសំណួរប្រឡងនិងលទ្ធផលដាក់ពិន្ទុ>

សភាកសិកម្មជាតិនឹងមិនឆ្លើយតបរាល់ការសាកសួរដែលពាក់ព័ន្ធនឹងសំណួរប្រឡងនិងលទ្ធផលដាក់ពិន្ទុទេ។

<ការហាមឃាត់ទង្វើខុសឆ្គង>

ក្នុងករណីបានប្រព្រឹត្តទង្វើដែលត្រូវបានចាត់ទុកថាជាទង្វើខុសឆ្គងដូចជា លួចចម្លង ប្រឡងជំនួស ធ្វើឲ្យបែកធ្លាយវិញ្ញាសាប្រឡងជាដើម សភាកសិកម្មជាតិអាចចាត់វិធានការដូចខាងក្រោម។
・ចាត់ទុកលទ្ធផលប្រឡង(រួមទាំងលទ្ធផលប្រឡងពីមុន)ជាមោឃ
・មិនជូនដំណឹងអំពីលទ្ធផលប្រឡង
・មិនអនុញ្ញាតឲ្យប្រឡងនៅពេលក្រោយទៀត

លើសពីនេះ សភាកសិកម្មជាតិក្នុងពេលតទៅមុខ នឹងមិនទទួលខុសត្រូវទាល់តែសោះចំពោះការខូចខាតដែលបេក្ខជនទទួលរងដែលជាលទ្ធផលនៃទង្វើខុសឆ្គងទេ។

<ការចាត់ចែងព័ត៌មានឯកជន>

ចំពោះលទ្ធផលប្រឡងនិងព័ត៌មានឯកជនដែលបានបញ្ចូលដើម្បីចុះឈ្មោះប្រឡងវាស់ស្ទង់សមត្ថភាពជំនាញកសិកម្ម(តទៅហៅថា “ការប្រឡងនេះ”) សភាកសិកម្មជាតិនឹងចាត់ចែងផ្អែកតាមបញ្ញត្តិដូចខាងក្រោម។

1. ការប្រើប្រាស់ព័ត៌មានឯកជន
សភាកសិកម្មជាតិចាត់ចែងព័ត៌មានឯកជនសម្រាប់តែគោលបំណងពាក់ព័ន្ធនឹងការប្រឡងនេះដោយប្រកាន់ខ្ជាប់ច្បាប់បទបញ្ញត្តិប្រទេសជប៉ុននិងសេចក្តីណែនាំដទៃដែលពាក់ព័ន្ធនឹងការការពារព័ត៌មានឯកជន។

បញ្ញត្តិការពារព័ត៌មានឯកជនសម្រាប់សភាកសិកម្មជាតិ
<< https://www.nca.or.jp/upload/rules_for_the_nca.pdf >>

2. អំពីការផ្តល់ព័ត៌មានឯកជនទៅជនទីបី
ព័ត៌មានឯកជនដែលទទួលបាន មិនត្រូវបង្ហាញឬផ្តល់ទៅជនទីបីលើកលែងតែករណីដូចខាងក្រោម។
・មានការយល់ព្រមពីសាមីខ្លួន
・ត្រូវបានទាមទារឲ្យបង្ហាញជាដើមនូវព័ត៌មានឯកជនផ្អែកតាមច្បាប់បទបញ្ញត្តិ
យ៉ាងណាមិញ
ករណីមានការសាកសួរអំពីលទ្ធផលនៃការប្រឡងនេះដោយហេតុផលសមស្របពីស្ថាប័នរដ្ឋាភិបាលនៃប្រទេសជប៉ុននិងប្រទេសដែលបញ្ជូនទៅដូចជានាយកដ្ឋានអន្តោប្រវេសន៍ គ្រឹះស្ថានអប់រំដូចជាសាកលវិទ្យាល័យ សហគ្រាសជាដើម សភាកសិកម្មជាតិនឹងឆ្លើយតប។

3. អំពីការពឹងពាក់ឲ្យចាត់ចែងព័ត៌មានឯកជន
អាចមានករណីពឹងពាក់ឲ្យចាត់ចែងព័ត៌មានឯកជនដោយមានការចុះកិច្ចសន្យាពាក់ព័ន្ធនឹងការការពារត្រឹមត្រូវនូវព័ត៌មានឯកជនជាមួយដៃគូដែលពឹងពាក់ការងារនៅក្នុងកម្រិតចាំបាច់ដើម្បីសម្រេចគោលបំណងក្នុងចំណុចទី1ខាងលើ។

## 2. ការចុះឈ្មោះព័ត៌មានលម្អិតផ្ទាល់ខ្លួន

| No. | សំណួរ | ចម្លើយ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ជម្រើសទី1 | ជម្រើសទី2 | ជម្រើសទី3 | ជម្រើសទី4 | ជម្រើសទី5 | ជម្រើសទី6 | ជម្រើសទី7 | ជម្រើសទី8 | ជម្រើសទី9 | ជម្រើសទី10 |
| 1 | សូមជ្រើសរើសថ្ងៃខែឆ្នាំកំណើត | 1930～ | 1～12 | 1～31 | | | | | | | |
| 2 | សូមជ្រើសរើសភេទរបស់លោកអ្នក | ស្រី | ប្រុស | | | | | | | | |
| 3 | សូមជ្រើសរើសសញ្ជាតិរបស់លោកអ្នក | ខ្មែរ | ចិន | ឥណ្ឌូនេស៊ី | ម៉ុងហ្គោល | មីយ៉ាន់ម៉ា | នេប៉ាល់ | ហ្វីលីពីន | ថៃ | វៀតណាម | ក្រៅពីនេះ |
| 4 | អ្នកធ្លាប់ទៅប្រទេសជប៉ុនឬទេ? បើធ្លាប់ សូមជ្រើសរើសគោលបំណងនៃការទៅប្រទេសជប៉ុន | មិនធ្លាប់ | ទេសចរណ៍ | សិក្សា | ហ្វឹកហ្វឺនសមត្ថភាពជំនាញ ហ្វឹកហាត់ការងារ | បម្រើការងារ | ក្រៅពីនេះ | | | | |
| 5 | អំពីការប្រឡងវាស់ស្ទង់សមត្ថភាពជំនាញកសិកម្ម សូមជ្រើសរើសរយៈពេលដែលបានសិក្សា | មិនលើស80ម៉ោង | 80ម៉ោង (ប្រហែល4ម៉ោងក្នុងមួយសប្តាហ៍ក្នុងពេល5ខែ) | 160ម៉ោង (ប្រហែល4ម៉ោងក្នុងមួយសប្តាហ៍ក្នុងពេល10ខែ) | 240ម៉ោង (ប្រហែល4ម៉ោងក្នុងមួយសប្តាហ៍ក្នុងពេល1ឆ្នាំ3ខែ) | 300ម៉ោង (ប្រហែល4ម៉ោងក្នុងមួយសប្តាហ៍ក្នុងពេល1ឆ្នាំ6ខែ) | ចាប់ពី300ម៉ោងឡើងទៅ | | | | |
| 6 | សូមជ្រើសរើសរយៈពេលធ្លាប់ធ្វើការងារកសិកម្ម។ | មិនធ្លាប់ | ក្រោម1ឆ្នាំ | 1ឆ្នាំ-2ឆ្នាំ | 2ឆ្នាំ-3ឆ្នាំ | 3ឆ្នាំ-4ឆ្នាំ | 4ឆ្នាំ-5ឆ្នាំ | 5ឆ្នាំឡើងទៅ | | | |
| 7 | តើអ្នកយល់ព្រមឲ្យផ្ញើព័ត៌មានស្វែងរកបុគ្គលិកផ្នែកកសិកម្មជាដើមនៅប្រទេសជប៉ុនទៅកាន់អ៊ីមែលដែលប្រើប្រាស់ក្នុងការចុះឈ្មោះប្រឡងដែរឬទេ? | យល់ព្រម | មិនយល់ព្រម | | | | | | | | |

## 3. ការប្រកាសលទ្ធផលប្រឡង




ចុចលើ **[Confirm]**។ គួរសំគាល់ថា បូតុង **[Confirm]** នឹងអាចចុចបាននៅពេលដែលលទ្ធផលប្រឡងត្រូវបានរៀបចំជាតារាងរួច។

## 3. ការប្រកាសលទ្ធផលប្រឡង

**農業技能測定試験結果通知書**
Notification of results for Agriculture skill assessment test

ASAT



| | |
|---|---|
| 受験番号<br>Registration Number | : 12345678 |
| 氏名<br>Name | : Joshua Santos Garcia |
| 国籍<br>Nationality | : Philippines |
| 生年月日<br>Date of birth | : 2000/01/31 (yyyy/mm/dd) |
| 性別<br>Sex | : Male |
| 受験地<br>Test location | : Philippines |
| 受験日<br>Test date | : 2019/10/30 (yyyy/mm/dd) |

គំរូ

試験の結果は以下の通りです。
Your test results are as follows.

| | |
|---|---|
| 試験名<br>Exam name | : General crop farming (English) |
| あなたの得点<br>Your score | : 73 |
| 試験結果<br>Exam result | : Pass |

各科目の正答率は以下の通りです。
The percentage of correct answers for each section are as follows.

Japanese language Exam : 75%

Crop Farming Exam : 75%

**本結果通知書は受験日から10年間有効です。**
The evaluation result notification is valid for 10 years from the date of test.

លទ្ធផលប្រឡងនឹងត្រូវបានបង្ហាញ។